មាត្រា ២ .-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## ២- សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០០

### សេចក្តីសំរេច លេខ ០៥ សសរ

### ស្តីពី ការផ្គត់ផ្គង់ទុក្ខសំភារៈ សំភារៈបរិក្ខារ និងការជួសជុលសាងសង់ ជូនក្រសួងអប់រំ យុវជន និងកីឡា

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមចំណារឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី២៤-៥-៩៩ និង ចុះថ្ងៃទី២៤-៧-៩៩ និងដើម្បីធានាប្រសិទ្ធភាព នៃការអនុវត្តន៏គោលនយោបាយរបស់រាជរដ្ឋាភិបាល

### សំរេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន ណាវី ហ្គាមិន អេន ត្រេដឌីង ( NAVY GARMENT & TRADING COMPANY) ធ្វើការផ្គត់ផ្គង់ ទុក្ខសំភារៈ គ្រឿងសង្ហារឹម សំភារៈការិយាល័យ សំភារៈរដ្ឋបាល ឧបករណ៍ ពិសោធន៏ និង វត្ថុធាតុដើម ស្នាដៃនិពន្ធ សំភារៈបរិក្ខារសេវាកម្ម បោះពុម្ពផ្នែកឧត្តមសិក្សា បោះពុម្ព សៀវភៅតាមកម្មវិធីសិក្សាថ្មីគ្រប់មុខវិជ្ជាសំរាប់សាលារៀនចំណេះទូទៅពីថ្នាក់ទី១ ដល់ថ្នាក់ទី១២ និងសេវាកម្ម ការផ្គត់ផ្គង់ តាមតម្រូវការចាំបាច់គ្រប់ផ្នែកទាំងអស់ និងគ្រប់បណ្តាគ្រឹះស្ថានឧត្តមសិក្សា មធ្យមបណ្តុះបណ្តាល មុខវិជ្ជាជីវៈ ជូនក្រសួងអប់រំ យុវជន និងកីឡា សំរាប់ឆ្នាំ២០០០ ដល់ឆ្នាំ ២០០៣ ដោយប្រើប្រាស់ថវិកាជំពូក ១១ ជំពូក ៥០.០១ ជំពូក៥០.០២ និងថវិកាជាតិត្រៀមបំរុងផ្សេងៗទៀត ។

ប្រការ ២ : អនុញ្ញាតអោយក្រុមហ៊ុន ងីម គីមឡេង អភិវឌ្ឍន៍ពាណិជ្ជ (NGIM KIM LENG DEVELOPMENT TRADING CO.,LTD ) ទទួលបន្ទុកក្នុងការសាងសង់ថ្មី និងការជួសជុលអាគាររដ្ឋបាល អាគារសិក្សាធំ-តូច ទាំងអស់ ជួសជុលបន្ទប់ពិសោធន៍ សាងសង់អាគារពិសោធន៍ ជួសជុលអាគារសិក្សា សាងសង់អាគារសិក្សា និងអន្តេវាសិកដ្ឋាន នៅតាមសាលារៀនចំណេះទូទៅ តាមសាលាគរុកោសល្យ វិក្រឹត្យការខេត្ត-ក្រុង និង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងរាល់សំណង់ទាំងអស់ជូនក្រសួងអប់រំ យុវជន និងកីឡា សំរាប់ ឆ្នាំ២០០០ ដល់ឆ្នាំ ២០០៣ ដោយប្រើប្រាស់ថវិកាជំពូក ១១ ជំពូក៥០.០១ ជំពូក៥០.០២ និងថវិកាជាតិត្រៀម បំរុងផ្សេងៗទៀត ។

ប្រការ ៣ : ចំពោះថ្លៃនៃការផ្គត់ផ្គង់ ទូតុសំភារៈ សំភារៈបរិក្ខារ និងការជួសជុលសាងសង់ទាំងអស់ដូចមានចែងក្នុង ប្រការ១ និងប្រការ២ ក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើការ ពិគ្រោះថ្លៃ ជាមួយក្រុមហ៊ុន ណាទី ឃ្លាមិន សេន គ្រេដឌីង និងក្រុមហ៊ុន ងីម គីមឡេង អភិវឌ្ឍន៍ពាណិជ្ជ អោយ បានសមស្រប និងពិនិត្យគុណភាពអោយបានច្បាស់លាស់ ។

ប្រការ ៤ : ចំពោះការផ្គត់ផ្គង់ ទូតុសំភារៈ សំភារៈបរិក្ខារ និងការជួសជុលសាងសង់ទាំងអស់ដូចមានចែងក្នុងប្រការ១ និងប្រការ២ ក្រុមហ៊ុនត្រូវធ្វើការផ្គត់ផ្គង់ និងជួសជុលសាងសង់ជូនមុន ហើយទូទាត់ជាក្រោយជាដំណាក់ៗ តាមថវិកាដែលមាន ។

ប្រការ ៥ : រាល់លិខិតបទដ្ឋានទាំងឡាយ ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០០

## សេចក្តីសំរេចលេខ ០៦ សសរ

## ស្តីពី ការបង្កើតគណៈកម្មការដោះស្រាយទំនាស់ដីធ្លីនេសាទ ជាមួយប្រជាជននៅស្រុកឯកភ្នំ ខេត្តបាត់ដំបង

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា